Khmer Story Lovers

នៃល្អងធូលី ។

កុំឲ្យវាគិត បារម្ភភ័យភិត ក្នុងឥន្ទ្រិយ
ទើបស្ដេចផ្ដែផ្ដាំ កិច្ចកម្មរាល់ទី ជាលោកគ្រូឈី–
លាផាប់វិលមក ។

សម្ដេចចៅហ្វា បានស្ដាប់ព្រះមហា ក្សត្រថ្លៃពន្លក
ទទួលទុក្ការ ក្រាបលាថយក្រោក ក្រុមរាំងដល់ទ្រោក
ជូនចេញមកក្រៅ ។

១០៣០– ដល់ទ្វារព្រលប់ ក្រុមរាំងឈរឈប់ ចៅហ្វាដើរទៅ
លុះដល់គ្រឹហា ភរិយាចៅពៅ ស្ទុះចេញមកក្រៅ
សួរសព្វប្រការ ។

ចៅហ្វាសោកថ្លែង ប្រាប់តាមដំណែង ដំណើរគោត្នា
សព្វគ្រប់រឿងរ៉ាវ ក្នុងក្រៅម្ដេចម្ដា ទើបហាមឃាត់ថា
មិនឲ្យស្រដី ។

ប្រាប់គេសព្វអ្នកផង ឲ្យដឹងទើមចង ពីព្រះចក្រី
ឲ្យដឹងតែបាន ប្រទានការថ្មី ជាឯកមន្ត្រី
សម្ដេចរាជា ។

ឯអ្នកស្រុកផង បានដឹងទំនង ជាអ្នកអាមាត្យ
បានបុណ្យជាធំ មកជុំចូលជា កូនក្មួយរាល់គ្នា



វិសេសស្ម័គ្រចិត្តផង ។

ពុំលន់សម្ដេច ចៅហ្វាបគ្រាប់ យកហិបទៅផង
អស់ទាំងបាវព្រាវ សេវសេន រសើបផាម្ដង
ស្ដាយដើរតាមទៅ ។

១០៣៥– ពុំលន់លុះដល់ ព្រះរាជមណ្ឌល មន្ទីរចៅពៅ
កូនក្មួយអស់នោះ ចាំនៅពេនក្រៅ មិនឲ្យចូលទៅ
ឯក្នុងខឿយនេះ ។

ចៅហ្វាខ្មះ- យកហិបមកដាក់ ថ្វាយក្សត្រាផៀស្ន័យ
សម្ដេចប្រើប្អូន យកកូនសោនេះ ទើបក្សត្រថ្លៃ
នាំយកមកថ្វាយ ។

ពោធិ៍សេដ្ឋា ស្ដែងស្ដេចទាក់សោ មើលទ្រព្យទាំងឡាយ
យល់យល់ពុំបាត់ ទើបក្សត្រពណ្ណរាយ ប្រាប់ថានាងអើយ
ហ៊ឹងហើយទ្រព្យនាង ។

កេសរមាលា ខ្ញុំដួនស្នេហ៍ភ្ងា ឲ្យភាន់រូបរាង
ទុកបញ្ចាំចិត្ត ព្រោះតៀងសំណាង សំណូមស្នមលាង
នៅពុំទាន់ដល់ ។

នាងនាថយល់ជាក់ ក្សត្រីទ្រង់លក្ខណ៍ ជឿអស់កិច្ចកល
ពុំមានសង្កា ចិត្តាពុំឆ្ងល់ ដឹងដោយយោបល់

ព្រះរាជហឫទ័យ ។

១០៤០– នាងថ្វាយបង្គំ ហើយនាងទូលថា យកទ្រព្យនោះនៃ
ដាក់ឲ្យស្រីការ រក្សាប្រពៃ ឯអន្តជៀសឆ្ងាយ
និរន្តរាជា ។

មានព្រះបន្ទូល ព្រះឱស្ឋមធុរ ពីរោះអស្ចារ្យ
និយាយរៀបរាប់ សាយសព្វប្រការ រឿងរ៉ាវម្តេចម្តា
មុនមានមកហើយ ។

សម្តេចចៅហ្វា ដឹងដោយប្រការ ដូច្នោះជាត្រើយ
ទើបថ្វាយបង្គំ ប្រណាម្យទូលឆ្លើយ ថាឯម្ចាស់អើយ
ថាបើដូច្នោះ ។

ម្តេចឡើយក្សត្រា មិនមានឧត្តរ ប្រាប់ពីកាលនោះ
នឹងគិតប្តីផ្តល់ ឲ្យយល់ចំពោះ ឲ្យដឹងត្រូវខុស
ដឹងខ្លួនខាងណា ។

ស្តេចបន្ទូលឆ្លើយ ថាលោកគ្រូអើយ ប្រាប់កំផងការ
ខ្លួនមួយកណ្តោច គ្រមោចកំព្រា អន្តផងទ្រព្យា
ក្តីណាទឹងបាន ។

១០៤៥– [illegible] កុំគិតសោកពេក គិតម្តេចក្តីប្រាណ
នឹងយកសេចក្តី អប្រិយសាធារណ៍ មកប្តីខាងល់បាន



ឲ្យរាងចាញ់ចាល ។

បុណ្យខ្ញុំជាស្តេច បើនឹងចង់កាប់ ចង់កិនមនុស្សពាល
បើចិត្តចង់ចាប់ ចង់កាប់ដោតក្បាល ចង់រោលចង់រាល
ឥឡូវក៏បាន ។

តែកុំធ្វើច្នោះ ធ្វើឲ្យឃើញខុស ឲ្យដឹងគ្រប់ប្រាណ
តែលោករកហេតុ ហាក់ឯងបំពាន បំពារបង់បាន
ចង់សាប់មានបុណ្យ ។

ចេះគួរយើងគិត ឲ្យត្រូវនឹងក្រិត្យ ឲ្យដឹងទោសគុណ
ឲ្យឃើញធ្ងន់ស្រាល យើងយកក្តីគុណា កុំឲ្យខុសស៊ុន
ក្រែងគេនិន្ទា ។

កាលនោះសម្តេច ចៅហ្វាគិតស្រេច ហើយទូលរាជា
បពិត្រចមចៅ គិតទៅឃើញថា ឲ្យមហាក្សត្រា
ដណ្តឹងម្តងទៀត ។

១០៥០– តែឲ្យព្រះចៅ កៀសខ្លួនចេញទៅ ជារាស្ត្រសឹកសេ
នៅដោយសារគេ រិះរេធ្លាសឆ្លៀត និតតែបែរបៀរ
ឲ្យបានជាសុខ ។

ហើយពឹងអ្នកនោះ ឲ្យជួយសង្គ្រោះ ជាជំហរគិត
ធ្វើជាអ្នកខ្មៅ ថែបូរស្មរចិត្ត សេដ្ឋីទុច្ចរិត

សមក្រេវក្រោធា ។

ស្រមីទ្រគោះ ប្រទះឈ្លុះឈ្លោះ បំពានបំពារ
យើងបានបទនោះ បំពោះហើយណា គិតឲ្យកើតជា

អត្ថអាថ៌សេចក្តី ។

ធ្វើពាក្យបោទបោះ ខ្តឹងទៅក្រមកោះ យកខ្លួនសេដ្ឋី
ស្តេចបន្ទូលថា លោកតាស្រដី គំនិតគិតថ្មី

ដូចខ្ញុំគិតគាប់ ។

បេះបូរលោកតា សរសេរធ្វើជា ប្រកាសមួយច្បាប់
ដាក់ថាព្រះរាជ ប្រកាសប្រាមប្រាថ់ ខ្ញុំរាជការគាប់

មាត្យមុខមន្ត្រី ។

១០៥៩– នូវរាស្ត្រប្រជា ចូរគិតគ្រប់គ្នា ទាំងអស់ប្រុសស្រី
ជាប៉េនរណា មានអាថ៌សេចក្តី កើតកេវហេតុអ្វី

វិភទនិងគ្នា ។

កុំចូលខ្លួលពិត ហើយឥឡូវតៀន ព្រះបាទរាជា
ស្តេចទ្រង់ប្រឈូន ព្រាយព្រះទយា ឲ្យប្តឹងទៅហ្វា

ជំនុំជំរះ ។

អស់សេចក្តីផង ថ្ងៃលកើតសៅហ្មង ឲ្យបានស្រឡះ
កើតក្តៅក្រហាយ ក្នុងកាយឲ្យជ្រះ ឲ្យបានសាន្តសះ



មន្ទិលតទៅ ។

ទៅហ្វាស្តែងស្តេច សរសេររួចស្រេច ព្រះបាទចមទៅ
បោះព្រះសង្ហារ ទៅហ្វានាំទៅ បិទមុងរោងក្រៅ

ឲ្យមើលរាល់គ្នា ។

លុះចូលពក្រី ព្រះបាទចក្រី ប្រាប់ព្រះប្អូនភ្លា
ដំណើររៀបរាប់ សាយសព្វប្រការ ហើយស្តេចលោមលា

រត្នរាជមហេសី ។

១០៦០– កៀលខ្លួនជាពស្ត្រ ស្រេចហើយយានយាស ទាំងយប់ពក្រី
លង់លុះដល់ផ្សារ ក្សត្រាធិបតី បរចូលទៅទី

រោងមួយណា ។

ប្រទះមេស្រុក អង្គុយប្រទុក នៅលើជើងមាំ
ចាំចិនដាក់មី ឲ្យស៊ីសោតណា លុះយល់ក្សត្រា

ចូលទៅហើយហោង ។

ពុំស្គាល់ក្សត្រា ជាម្ចាស់អាត្មា ថែលគិតជាម្តង
យល់យន់រូបកាយ ទ្រង់ទ្រាយហ្មត់ហ្មង មានចិត្តស្នេហ៍ស្នង

ស្រឡាញ់ពេកក្រៃ ។

ហៅថាមហាមិត្រ អញ្ជើញមកជិត មកឯនេះនៃ
សម្តេចរាជា លីលាចូលវៃ មេស្រុកលួកដៃ

ចាប់ព្រះហត្ថ ។

ឲ្យអង្គុយជិត ហើយសួរថាមិត្រ ស្រុកទេសអ្នកណា
ចូរអ្នកប្រាយប្រាប់ មកឆាប់សូរ៉ា អ្នកមកនេណា
ប្រាជ្ញាកស្តុតី ។

១០៦៩- ពោធិសត្វឆ្លើយ ថាហៃមិត្រអើយ ស្រុកឆ្ងាយណាស់នៃ
ខ្ញាមកចាំហៃ ព្រះបាទចក្រី ជាមកុដសិរសី
ឥសូរលោក ។

ខ្ញាមកនេះគួរ ប្រយោជន៍តានៅ រកផ្ទះដោយសារ
ទំរាំព្រះចៅ យាងទៅកាលណា សឹមយើងយាត្រា
ទៅកាលនោះនៃ ។

នៅជិតពន្លា នាំឲ្យគេថា វិវរពេកក្រៃ
មេស្រុកស្តាប់ហើយ ឆ្លាស់ឆ្លើយថាហៃ មិត្រអើយកុំភ័យ
ទៅនៅនឹងខ្ញា ។

បិនដាក់មិបាន ជួសដាក់ផល់តាន ថ្កល់លើតុក
ពោរពេញប្រអើរ បន្ទើះស្លាបព្រា ដាក់រៀបត្រៀបត្រា
ជាដាក់ពុនថៅ ។

មេស្រុកស្រដី ថាមិត្រមកវ៉ុ ញុំតម៉ក្តៅ ។
ពោធិប្រសើរ ថាអើហូបទៅ មេស្រុកហៅរ៉ៅ



ចាប់ភាញហត្ថ ។

១០៧០- ព្រះពង្សពោធិ៍ ឲ្យស្តេចសោយមី ជាមួយភាគ្នា
ហេតុតែពុំស្គាល់ ពូជពាពង្ស គន់គិតស្មានថា
ជារាស្ត្រវិស័យ ។

ពង្សពោធិ៍ហៅ ស្តេចបរចូរទៅ សោយមីនោះនៃ
នឹងមេស្រុកមិត្រ អស់ឥតសំចៃ ស្រេចលែងហើយនៃ
មេស្រុកនោះណា ។

នានាំព្រះអង្គ លីលាគ្រាប់ត្រង់ ទៅផ្ទះភាគ្នា
ដល់ហើយឡើងទៅ ហាហៅករិយា ឲ្យមកម្ចីម្ចា
សំពះពោធិ៍ ។

## បទព្រហ្មគីតិ

នេះបទព្រហ្មគីតិស្មើរ ដំណើរនេះនឹងថ្លែងពី
នោមយន់អគ្គនារី នៃនាងកេសរមាលា ។
តាំងតែពីឃ្លាតអង្គ ព្រះទេវវង្សទៅកាលណា
កាលនោះនាងសោកា តែងរលឹកនឹកសព្វថ្ងៃ ។
លាក់ខ្លួនពួនរងទុក្ខ ខ្លាចផុតពុកមីងជេរវ៉ៃ
រំពឹងរឹងរៃ ពិតពុំដែលសែនសប្បាយ ។
រលឹកនឹកវិញស្រក ស្រើរនឹងនឹកពកព្រាយ

ញាក់ញើមរុះរាត់កាយ ខ្លាំងបេញពីអង្គកាយា

៦៨៥– នឹកខ្ញាល់កែកក្នុងពោះ ជាទុក្ខប្រុសថ្លៃសង្សារ

អកតៅតាលក្សត្រា ម្តេចជេដ្ឋាបាត់អម្ពាយ

អម្បាលគេពៅផង នឹងអ្នកបងស្រស់នោមឆាយ

គេវៀលតែរាល់កាយ បាត់តែអ្នកថ្ងុរះអើ

ឬក្រែងអ្នកប្រុសពៅ បានទៅដល់កន្លុរី

ចូលផ្គាប់ផ្គុនចក្រី ជាម្ចាស់លើសរសា

បំរើព្រះបមក្សត្រ បានជាបាត់ដូច្នេះណា

ឬនអ្នកនឹកសង្កា សង្ស័យចិត្តផងឯស្បើយ

នឹងទៅសួរអាចារ្យ ទាយបែកការពុំឃ្លាតឡើយ

តាលណាលអ្នកថ្លៃអើយ មិនដឹងកែថែរបេះណា

៦៩០– ប្រសិទ្ធបូនបេះបោះ នឹងហើរផ្លោះដោយវេហាស៍

ទៅតាមតាមចិន្តា ឲ្យបានដល់យល់ប្រុសថ្លៃ

សួរសាការកិច្ចកល សោះតិតចល់ចិត្តសង្ស័យ

គង្វល់ក្រៃក្រៃ មិនដឹងត្រិះរិះថែបណា

នាងតែងប៉ៃបែរបែក ចិត្តរំលែកច្រើនប្រការ

ប្រកាន់តែទុក្ខា ជានិរន្តរ៍ពុំមានសើយ

តែងសោកសៅសញ្ជប់ ទុនទ្រៀវជ្រប់កល់កៀកកើយ



ទឹកនេត្រហូរជាប់ឡើយ ស្រក់ជោកជាំជាប្រក្រតី

សោកសព្វគ្រប់វេលា លង់លុះជាចូលឆ្នាំថ្មី

រីឯថែមទុក្ខថ្មី ១ បុណ្យជួបចប់គ្រប់សព្វា

៦៩៥– រីឯគិតរឹងចង្អៀត ក្នុងទ្រូងទៀតអួលអន់ផ្សា

គន់គិតក្នុងចិន្តា ទុអ្នកប្រុសកំសត់ម្ល៉ូន

ជួបចប់គ្រប់ឆ្នាំហើយ ប្រុសប្អូនអើយម្តេចបាត់សូន្យ

បាត់សោះមោះមែនម្លួន មិនឃើញមកកេប្អូនស្រី

ទុះបើបាត់អ្នកថ្លៃ ទៃមុខទៃមិនឃើញទៀត

សម្លាប់មែនដូចស្តី ប្រាកដពិតពុំខានឡើយ

នាងបើកបង្អួចប្រាង្គ ប្រាសាទនាងជាក់ទើបថើយ

មើលមេឃក្រឡេកកៀវ យល់ពពកព្រះពាយផ្ទុំ

អណ្តែតមកពីឆ្ងាយ លឿនក្រសាយទៅគ្រប់

រឺងទឹកលើកយំ ខ្ញាល់ថែជាទុពពក

៧០០– ព្រះពាយរំកាយផាត់ ចក់សោត់ផងផ្គុំមក

បាត់តែប្រុសពន្លក មើចមិនមកកេកានប្អូន

ប្អូនយល់ពពកហើយ ព្រះពាយអើយផាត់ប្រពួន

ប្រពាក់សាត់ជួបផ្ទួន មកផង្គុំប្រជុំគ្នា

ប្អូនព្យាសម្ដែងវិរ ទឹកស្រៃថែប្រុសពុំគា

ហាក់ដូចអ្នកលីលា ស្ទះស្ទើរមករកប្អូនស្រី ៗ
ផ្គរលាន់រន្ទាន់ឆ្ងើយ ទ្រៃថ្ងៃអើយអ្នកថៃថ្លី
អ្នកទៅគាល់ចក្រី ខានពុំបានមកជិតអី ៗ
ហើយប្អូនផ្តាំផ្តើ ឲ្យមោះមកប្រាប់ប្អូនស្រី ៗ
រំពុករំពើកខ្ទី ខផ្គរអើយសូមមេត្តា ៗ
៧០៩– ការណ៍កនាំពតិមាន ទៅប្រាប់ប្រាណប្រុសសង្សារ
ឲ្យអ្នកទំយាត្រា វិលវិនមករកប្អូនស្រី ៗ
នាងសោកសែនផ្លូល លន់លុះចូលផ្គូបក្រើ
នារីត្អូតពិស យកទៀនធូបនូវភ្ញា ៗ
ជោគជាក់គម្កល់លើ ពានប្រសើរសុវណ្ណ
ថ្វាយអស់តាំងទេវតា ខ្ញុំអង្គកាយថ្វាយបង្គំ ៗ
នឹកផ្សេងក្នុងចិត្តថា ឱទេវតាសូមជួយខ្ញុំ
ឲ្យបានប្រាណជួបជុំ ទីឯស្វាមីប្តីបុកណា ៗ
ឲ្យមិត្រឲ្យមូលគ្នា ក្នុងមាសានេះកុំខាន
ផ្សេងស្រេចនាងកល្យាណ ប្រះកាយាទិត្រាទៅ ៗ
៧១០– ប្រចាំប្រាំប្រចិត្ត កែនគន់គិតក្នុកក្តលក្តា
អម្ពុនលុះយប់ជ្រៅ នាងបានលក់យល់សប្តសាយ ៗ
ហាក់ដូចតាសមួយណា ចរយាត្រាមកពីឆ្ងាយ



ស្រគត់ស្រគំកាយ កាន់ចិញ្ចៀនត្បូងពេជ្រខ្ទី :
នាំមកលក់ឲ្យនាង ទៅជិតខាងកោតសេដ្ឋី :
នាងយល់ចិញ្ចៀនខ្ទី មានចិត្តអស្រឡាញ់ក្រៃ ៗ
គិតចង់ទិញយកទុក ខ្លាចផុតក្រែងផងវៃ
ក្នុងអង្គចង់បានក្រៃ ហើយយល់ហាក់ខ្លាចសេដ្ឋី ៗ
ទិញនៅផ្សេរបណ្ដាញ ដូច្នោះមិញទៅបាត់ខ្ទី
យល់ដូចផុតកស្ដី ថាពុំឲ្យនាងយកឡើយ ៗ
៧១៥– ដូនវិញចេញបាត់ទៅ នាងសោកសៅឥតឯស្បើយ
នឹកស្ដាយមិនមានល្ហើយ គិតចង់បានចិញ្ចៀនក្រៃ ៗ
សោយសោកលន់នៅគិត ស្រាប់តែលេចចិញ្ចៀនថ្ងៃ
អណ្ដែតឡើងលើព្ធ ឯអាកាសវេហាស៍ផ្សេង ៗ
រស្មីភ្លឺចែងចាំង ត្រះខ្ទូតាំងផែនភពផង
អណ្ដែតមកជាម្ដង ធ្លាក់ចុះចំក្នុងម្រាមដៃ ៗ
នាងអរផុតឧបមា ហើយដូចជានាងស្រីថ្លៃ
អណ្ដែតចេញក្រៀវក្រេ ឡើងលើឯអាកាសហាន ៗ
មានសេក្តូចក្រឆាយ បើកបាំងកាយនាងកល្យាណ
នាងភ្ញាក់ពាក់សយដ្ឋាន នឹកថាឱអញយល់សប្ត ៗ
៧២០– ចាំឲ្យកវែថ្ងូកកន្ទុង តាមទំនងនិមិត្តសប្ត

ចំណៀននាសទឹកដប់ ដែលជូនចាស់នាំមកនោះ ។
ពិតជារៀមកស្ដា ដែលមាតានាំមកផ្ដោះ
ផ្ញុកផេរបន្ទោស កាយបណ្ដាញបរបេញទៅ ។
ព្រោះក្បិតគិតសេល់ មិនបង់យល់ឲ្យមូលនៅ
អ្នកប្រសអ្នកប្រាសទៅ ចាកចោលប្អូនសូន្យជ្រងំ ។
ចំណៀនអណ្ដូកមក ដូចគេសិកម្រាមដៃខ្ញុំ
អ្នកមានបុណ្យជាធំ ប្រាកដពិតពុំឃ្លាឃ្លាត ។
ឯអង្គខ្ញុំអណ្ដូក តិតតាមហេតុនិមិត្តជាតិ
អ្នកប្រុសថ្ងៃនោមស្អាត បានជួបខ្ញុំនាំយកទៅ ។
៧២៤– ហេតុនាងជាកន្សែ ប្រាជ្ញាវៃប្រាជ្ញជ្រះជ្រៅ
កាត់សង្កិតសល់នៅ នឹករើកអន់ទុក្ខា ។
ក្រោកក្រាកចាកចេញក្រៅ ស្រស់នោមទៅលុបកក្ដា
ហើយនាងនាថសុំស្វា ឯអង្គកាយមិនមានកែន ។
តែសក់នាងមិនមានសិក មិនមានស្បិតតិតនឹងល្បែង
អង្គុយតែឯកឯង គ្មាននិយាយនឹងនរណា ។
នាងបើកបង្អួចនៅ ចាំមើលផ្លូវនៃកស្ដា
កល់ពេលកល់វេលា លង់លុះគ្រាតែស្ដេចដល់ ។
ព្រះបាទប្រជានណា ព្រះពន្លាជាសកល



គ្មាននឹងដំណឹងផល់ ក្រែកករសល់ផងទុបមា ។
៧៣៣– គាត់នឹកបំផ្លាញ ព្រះពមរៅស្ដេចយាត្រា
មកដល់នេះហើយណា ស្ដេចផ្ដាំថ្ងៃប្អូនបាត់ ។
ឬមួយស្ដេចឲ្យអ្នក ទៅពីនគាក់បាំងកាត់
ក្រែងក្រុងឯក្អែងស្ងាត់ អ្នកនឹងកាត់មកពុំខាន ។
នាងគន់នាងគិតគ្រប់ កើតថែវបប់បារម្ភមាន
ខ្ញុញយំពុំស្រាកស្រាន្ត ចាំនៃថ្ងៃយប់គ្រប់វេលា ។
នឹងថ្លៃនៃនឹងទៀតទៅ ឯព្រះទៅបរលោកា
នៅនឹងមេស្រុកជា- ទុក្ខនឹកដល់និមិលមិត្រ ។
ដុំនៅផ្ដុំមេស្រុក ពុំសាន្តសុខតែងគន់គិត
ការណាបន្ទាបកាណិត ដុំពុំលេកលុះព្រឹកព្រាង ។
៧៣៤– សម្ដេចព្រះទិនករ ស្ដេចបើកបរកាជរថវាង
វិលវង់គ្រង់ទៅខាង ទិសបូព៌ាបរវៀងរ៉ះ ។
លឿនលេចរំពេចភ្នែក ខ្ពស់ត្រៃដែកភ្លឺគ្រប់ៈ
មិនមានគតកប៉ះ ជាសំពេញជំគ្រប់ដែន ។
ប្រជាជនតាំងឡាយ ភ្ញាក់ពល់កាយរៀបការកែន
រកស៊ីតាមដំណែង ដំណែលដែលប្រសព្វមក ។
សម្ដេចព្រះទៅវង្ស ពម្សូរពង្សពុទ្ធពន្ធក

ព្រះអង្គស្តេចតើនក្រោក    ចាកនិទ្រាលីលាចេញ ។
ស្រប់កគ្រុឌកាប់យក    ព្រះស្រីមកមានពោរពេញ
សោយស្រេបស្តេចគិតការញ    នឹងមេស្រុកជាយើរ៉ី ។
៧៦០– សូមមិត្រការណ៍គគ្នា    ឯងលីលាចូលទៅខ្មី
ដណ្តឹងកូនសេដ្ឋី    នេះឲ្យគ្នាហ៊ានឬទេ ។
ជាប៉េឯងស្រឡាញ់    អាល័យអញកុំវេះវៃ
មេស្រុកឆ្លើយជាមេ    ម្តេចហ៊ានពារហ៊ានពុះម៉ោះ ។
មិត្រឯងមកពីឆ្ងាយ    ឯកអង្គកាយឥតញាតិសោះ
ឯការឥតកេរ្តិ៍កោះ    យសគុណគាប់ចាប់ពាន់ពេក ។
ក្រែងគេមិនមេត្តា    ត្បិតគេជាសេដ្ឋីឯក
សម្បត្តិច្រើនអនេក    ជាធំលើសអ្នកនានា ។
ក្រែងតែគេមិនឲ្យ    កាស៊ិនសិយឯកាគ្នា
អន្តអញឥតបើជា    មិត្រប្រើទៅនឹងជាអ្វី ។
៧៦៥– គ្រាន់បានមិនបានមិត្រ    កុំអន់ចិត្តអាក់ទើងអី
ប៉ុណ្ណោះមិនក្រក្រី    មិត្រឲ្យអញទៅជាម្តេច ។
ចមតន្ត្រីព្រែងមហាក្សត្រ    បន្ទូលថ្វាត់ប្រាប់កលកិច្ច
កាមជោយនូវកលល្បិច    គន្លងមុខមានមកហើយ ។
ទើបយកប្រាក់ឲ្យទៅ    មេស្រុកទូវពុំលន់ឡើយ



ទិញអស់កស្តុជាត្រើយ    តាមសមគួរដូចធម្មតា ។
បានស្រេចគ្រប់ពិត    មេស្រុកមិត្រតែងគ្នា
សព្វគ្រប់ចរយាត្រា    នានាំអស់គោដន់ចំណី ។
លលាំទលលះ    លុះដល់ផ្ទះភោគសេដ្ឋី
កុនចិត្តគិតសេចក្តី    ប្រយ័ត្នទុកឲ្យចាំនៅ ។
៧៧០– លុះឡើងលើមណ្ឌល    សេដ្ឋីយល់ហើយហាហៅ
មេស្រុកចរចូលទៅ    អង្គុយជិតមហាសេដ្ឋី ។
លើកដៃសំពះគ្រោះ    សេដ្ឋីនោះដណ្តឹងខ្មី
មេស្រុកមករកអ្វី    ចូរស្រដីជាទៅចុះ ។
បូចន៍ចង់ការប្រាក់    ក្រែងជាំពាក់គេឯណោះ
កុំអៀនអន់អេះអុះ    ចង់រកអ្វីស្តីកុំខ្លាច ។
មេស្រុកឮសេដ្ឋី    ឲ្យសំដីព្រោះឯងអាច
នឹងបានមានអំណាច    ទើបជំរាបតាមសេចក្តី ។
សូមទានទុំជំរាប    សូមឲ្យជ្រាបការណ៍នោះនៃ
ខ្ញុំសូត្រអត់ទោសពៃរ៍    កុំប្រកាន់ប្រកួតឡើយ ។
៧៧៥– ត្បិតមានកំលោះម្នាក់    មកពីជាក់ខ្ញុំបាទហើយ
រៀបរាប់ប្រាប់ជាត្រើយ    ជាមានចិត្តគិតអាល័យ ។
ចង់ចូលចងជាស្ពាន    ចិត្តបង់បានបុត្រីថ្លៃ

Khmer Story Lovers

ជាគួគាប់ប្រពៃ ទើបឲ្យខ្ញុំមកប្រណិប័តន៍ ៗ
ជំរាបលោកសេដ្ឋី សូមប្រណីសង្គ្រោះសត្វ
ឲ្យមូលកុំឲ្យព្រាត់ និងរៀបអស់បណ្ណាការ ៗ
ចូលមកក្រាបសំពះ ទូលលោកម្ចាស់ជាបិតា
មាតាតាមបុរាណ តម្រាព្រេងពីមុនមក ៗ
មួយបើចិត្តលោកម្ចាស់ ឲ្យសង់ផ្ទះគ្នាតរេ
ឲ្យបានតែភព្វក បុត្រជាមិត្រស្និទ្ធមេត្រី ៗ
៧៦១– មេស្រុកជំរាបហើយ កុំលង់ឡើយឯសេដ្ឋី
សួរសព្ទឡប់ទៅវិញ ឯណាមួយមេស្រុកអើយ ៗ
ចូរឯងវែងវេរា ប្រាយប្រាប់គ្នាកុំលាក់ឡើយ
ទៀតទើបមេស្រុកឆ្លើយ ជាបពិត្រលោកសេដ្ឋី ៗ
រីឯខ្លួនអ្នកហ្នឹង ខ្ញុំពុំដឹងជាឈ្មោះអ្វី
ជាមានឬក្រក្ដី ខ្ញុំពុំស្គាល់ដល់តិចតួច ៗ
តែមើលសព្វសព្វាង្គ សង្កេតពង់មិនអ្នកខូច
មើលឫកពាំងពីតូច មកសំណាក់នឹងខ្ញុំបាទ ៗ
យ៉ាងជាកូនអ្នកមាន ទ្រព្យធនធានធារស្អាត
បើក្រម្ដេចហ៊ានភាគ ពីងខ្ញុំមកក្រាបប្រណិបតន៍ ៗ
៧៦៨– មួយទៀតក្នុងគាត់ថា លោកសន្យាពាក្យកាន់កាត់



មុននឹងផុតគាត់ ត្បិតជាក្មេងនៅខ្ចីគ្នា ៗ
ជាផ្ទៀងនឹងស្រីគ្នា ឲ្យទៅគាត់ជាភរិយា
ឥឡូវនេះបានជា គាត់ពីងខ្ញុំសូមសួរលោក ៗ
តើមែនពុំមែនក្ដី សូមប្រណីអត់អធ្យាក
កុំឲ្យមានស្នាក់ស្នោក ប្រកាន់ទោសអួសជំនើរ ៗ
សេដ្ឋីស្ដាប់មេស្រុក កើតវិតក្កគិតជាយើ
អាវែងនោះខេតេ ភាចខូចមិនព្រមលែង ៗ
ខ្លួនវាក់ព្រាព្រួយ តែក្បាលមួយម្ដេចមិនក្រែង
មិនកោតអង្គអញឯង ទំផែតកាឆ្លើយមកទៀត ៗ
៧៧០– ពីមុននៅឆ្ងាយរាំ នាំលិលាចចូលបៀត
ខ្លួនក្របង់ពោលមៀត ចង់ផ្ទេកស៊ីទ្រព្យគេមាន ៗ
សេដ្ឋីគិតថ្ងោះ វិងញីរពោះពន់ប្រមាណ
ប្រមាថជៀលដល់ប្រាណ ព្រះពន្សពោធិសត្វា ៗ
នឹកខឹងនឹងមេស្រុក ខំអត់ទុកនៅក្នុងប្រាណ
ធ្វើស្រួលស្រដីថា នៃមេស្រុកឯងចាំទុក ៗ
អញអត់ម្ដងនេះណា ត្បិតយល់គ្នាជាអ្នកមុខ
កុំធ្វើស៊ិកគ្រលុក យ៉ាងផ្ដេសផ្ដាសដូចមុនក្រោយ ៗ
អាយុរៀបទៅកាជ នៅតែឆោតដើរអន្ទ្រៃយ

មនុស្សអ័កក់ក្រោយ　　គេបញ្ឆោតមកឲ្យស្លាប់ ៗ

៧៧៩– នេះប៉ុន្តែអញយល់　　អន្ទឹកល់អញឲ្យកាប់

ធ្វើមីងមិនដឹងច្បាប់　　មកបង្អាប់បង្អោនគេ ៗ

អញនេះមិនដែលទៅ　　ស្គាល់ម៉ែឪសាន្ទុះទេ

ករេករះរេ　　ចាំតែក្តាសតែពាសទៅ ៗ

អញជាសេដ្ឋីខ្ពស់　　ខ្ទង់នោះប្រៀបដូចស្មៅ

ដើនក្រាស់ក្រាបញ្ញានៅ　　ដីក្រួសថ្មក្រលូកលាស់ ៗ

គួរប្តូរមស្រុកឯង　　មកទិនក្រែងមិនគោគសារ

មនុស្សថោកយ៉ាងម្នាះ ៗ　　ហ៊ានធានា នាំពាំយកមក ៗ

ណ្ហើយចុះខុសម្តងអញ　　អញមិនកាញ់មិនគិតយក

ទោសគេកុំរេក　　ពាំពាក្យមកវិញទៀតថ្មី ៗ

៧៨០– ទៅផ្ទះទៅវិញចុះ　　មេស្រុកនោះស្តាប់សេដ្ឋី

ក្រាបលារពេចទី　　ចរចុះដើរលេលើទៅ ៗ

ដល់លើផ្ទះហាទបិត　　ប្រាយប្រាប់មិត្រដូចដោយនូវ

ពាក្យសេដ្ឋីកំឡៅ　　ដំណាលគ្រប់សព្វប្រការ ៗ

ត្រង់ឲ្យមិនឲ្យនោះ　　គ្មានពាក្យសោះមិនពុថា

ពុំទាន់បានដឹងការណ៍　　ចេះតែមិត្រគិតដូចម្តេច ៗ

ពង្សពោធិសត្វធ្វើយ　　ថាមិត្រអើយគ្មានកលកិច្ច ·



អញចង់លបខ្ទិច　　ទៀតចង់ដឹងតែសំដី ៗ

ថ្ងៃស្អែកឯងទៅទៀត　　ទំនាស់ទៀតសួរសេដ្ឋី

យើងយកតែផ្លូវក្តី　　លេងសេដ្ឋីនេះបានម្តង ៗ

៧៨៩– លុះចូលកាត្រីជួប　　ព្រះចក្រជាតិជាច្បង

ស្តេចសោយអាហារផង　　ជាមួយមិត្រស្និទ្ធស្នេហ៍ស្នាល ៗ

មិនមានឲ្យអាក់ចិត្ត　　ស្រឡាញ់មិត្រស្និទ្ធស្នេហ៍ស្នាល

និយាយកាយដំណាល　　ពីនេះនោះលុះដល់ផ្ទុំ ៗ

ស្តេចចូលទីសយនា　　ព្រះទយាវិនបារម្ភ

គិតដល់នាងឧត្តម　　នឹកជាមាសបងអើយ ៗ

សមស្ងួនប្រាណព្រួយខ្លួន　　កែនកែកក្អន្ទផតស្បើយ

ពុថាបងដល់ហើយ　　ឱម្ទេះចិត្តបងជួបក្រៃ :

សមប្អូនមាសព្រះលឹង　　កែនទខ្ទង់កែសព្វថ្ងៃ

ម្ទេះសមម៉ឺមាសថ្លៃ　　ដឹងជាបងឲ្យចូលគិត :

៧៩០– ដណ្តឹងដល់សេដ្ឋី　　សូមប្អូនស្រីសមមេត្រ

ម្ទេះហើយសមគ័យគិត　　ក្បិតផុតពុកមិនមេត្តា ·

ក្រែងខានមិនបានជិត　　ជួបស្នេហ៍ស្និទ្ធរួមដាក់

ក្រែងបងខ្លាចបិតា　　ពិតពុំហ៊ានចូលស្តីទៀត ·

ស្ងួនអើយម្ទេះសមរៀម　　មិនឈប់ស្ងៀមឲ្យបងស្បៀត

ស្ដេចម្ដាផ្ដាំទៀត　　គិតយកប្អូនឲ្យគ្រាមុន ៗ
ស្ដេចគិតព្រះប្អូនស្រី　　សព្វសេចក្ដីទើបប្រុសព្រួយណោះ
ផ្ដិលក់ជាសុខសាន្ត　　លុះព្រឹកព្រាងស្វាងសុរិយា ៗ
ស្ដេចតើនចាកបន្ទំ　　ក្សត្រខ្ពង់ស្រេចបក្ដ្រា
ស្រេចហើយព្រះជា　　សោយព្រះស្រីស្រេចហ្នត់ហ្នង ៗ
៣៩៥– ស្ដេចហៅមេស្រុកមិត្រ　　ចូលមកជិតក្សត្រច្បាស់ច្បង
សំណេះសំណាលសាសង　　ថាហៃមិត្រអាណិតគ្នា ៗ
ឯងទៅសួរសេដ្ឋី　　ចង់ដឹងក្ដីកាចឬជា
សួរគាត់ឲ្យច្បាស់ការណ៍　　ជាគាត់ឲ្យឬមិនឲ្យ ៗ
គោះប៉ះគេភ័យជំ　　ស្ដេចផ្ដាំអស់ជាក្រោយ
ឯងគិតកុំឲ្យឆ្ងាយ　　ប្រាណប្រុងគេបោះឲ្យរួច ៗ
មេស្រុកស្ដាប់ពាក្យមិត្រ　　មិនអាក់ចិត្តដល់ពិចត្តួ
ហេតុចិត្តគិតកាន់គួច　　ស្រឡាញ់ពន្យះពោធិសត្វ ៗ
រៀបខ្លួនស្រេចចុះដើរ　　ទៅលះលើលុះដល់ថ្នាក់
ឡើងលើក្រោបប្រណិប័តន៍　　ឯសេដ្ឋីយល់ហើយណា ៗ
៤០០– ទេវទីងសម្ដីមុខ　　ស្រែកជេរផុកឯក្រោយថា
មេស្រុកដួលពោហោ　　មករកក្មួយញាទៀតហើយ ៗ
ឲ្យលេមិញអញបានហាម　　កុំមករំលាំឡើយ



មេស្រុកក្បៀតគ្នាស់ឆ្លើយ　　ថាលោកអើយកុំអាលជេរ ៗ
ខ្ញុំមកមិនជ្រួលជ្រើម　　ជ្រៀតជណ្ដើមកូនលោកទេ
មកនេះព្រោះតែគេ　　ប្រើឲ្យមកសូមសួរលោក ៗ
ឲ្យអស់តែប្រសាសន៍　　ជាស្រឡះអត់អញោក
ហើយឬនឹងយល់យោគ　　ឲ្យចងចូលស្ពានមេត្រី ៗ
អាសូរជាកូនចៅ　　ឬមួយទៅសូមប្រណី
កាលនោះឯសេដ្ឋី　　ស្ដាប់មេស្រុករំភុកពោះ ៗ
៤០៥– ខឹងក្ដាញ់ក្នុងចិត្តា　　ស្រដីថាឯងទៅចុះ
ប្រាយប្រាប់អាផែនោះ　　កុំឲ្យរាំគិតសង្ស័យ ៗ
ថាអញមិនឲ្យទេ　　សូវឲ្យផ្ដក់ជាក្រៃ
ជាជាងមុខរាំង　　ចិត្តសាមាឲ្យហ៊ានថ្លើមធំ ៗ
អម្បូរបាយសិង្ហាផង　　មកប្រមាថកន្ទោងចំ
មានសក្តិថ្លៃឧត្ដម　　មិនបានទេកុំស្រមៃ ៗ
រីឯមេស្រុកនោះ　　បានឮពោះលាវិលវៃ
បានដល់ផ្ទះហើយនៃ　　និយាយប្រាប់តាមចំនង ៗ
ពោធិមុនីនាថ　　ដឹងជោយកាចអស់ដើមទង
ស្ដេចឆ្លើយទៅវិញស្នង　　ថាហៃមិត្រសំឡាញ់អើយ ៗ
៤១០– ឯងកុំបារម្ភគិត　　អាក់អន់ចិត្តនឹងគ្នាឡើយ

ជួយគ្នាឲ្យដល់ត្រើយ    គ្នាមិនឲ្យសោះឡោះទេ ។
គ្នាគិតឲ្យឯងសុខ    បានជំមុខមាត់ខឹងគេ
មិនឲ្យនៅទំនេរ    ជាមេស្រុកជូះឡោះឡើយ ។
មេស្រុកស្ដាប់មហាមិត្រ    ជូះឡោះពិតនោះស្រេចហើយ
ត្រេកអរក្រែកឯស្បើយ    ទើបស្រដីទៅវិញថា ។
មិត្រអើយឯងកុំគិត    បារម្ភចិត្តគ្នាឡើយណា
ឯងប្រើជួបម្ដចម្ដា    គ្នាមិនមានហានជាអ្វី ។
ព្រះពោធិសត្វឆ្លើយ    ថាមិត្រអើយឯងស្រដី
ឃើញចិត្តមិត្រប្រណី    ស្រឡាញ់ស្មោះចំពោះពិត ។
៨១៥ - ពន្យល់ពីរនិយាយគ្នា    លុះសុទ្ធិយាមពន់ងងឹត
ដំធុំដំរះគិត    រកកលកែបែបយ៉ាងណា ។
គិតស្រេចស្ដេចចូលផ្ទំ    ក្នុងបន្ទំទីសយនា
លុះព្រឹកព្រះសុរិយា    ភ្លឺស្រេចស្រាន់បំព្រានជាក់ ។
ស្ដេចតើនតាកបន្ទំ    ក្សត្រខត្តមស្រប់ព្រះភក្ត្រ
ស្រេចហើយព្រះទ្រង់លក្ខណ៍    សោយព្រះស្រីស្រេចជាមួន ។
ស្ដេចហៅមេស្រុកមិត្រ    ចូលមកជិតហើយសាសង
សាសន៍ប្រាប់ទំនង    ថាមិត្តអើយឯងទៅទៀត
តោះបើសេដ្ឋីនោះ    ទឹងទ្រគោះកុំទំធ្មៀត



ធ្វើយជាក់ចំលាក់ស្មៀត    ប្រាប់ថាមុខជាមិនហើយ ។
៨២០– បើសេដ្ឋីនោះនៃ    ទឹងផរវៃឯងជាត្រើយ
ឲ្យឃើញចុះវ៉ាអើយ    យើងអត់ខនយានយកច្បាប់ ។
មេស្រុកបានស្ដាប់ហើយ    ពុំលន់ឡើយចុះទៅឆាប់
លះលើដើរប្រញាប់    លុះបានដល់ផ្ទះសេដ្ឋី ។
ឈានដើរឡើងលើផ្ទះ    ក្រាបសំពះជំកបខ្មី
ថាលោកមិនប្រណី    ប្អាច់សោះទៅជាមួន ។
៨២៣ – បើជាក់ជាដាច់សោះ    កោះដើងកោះរកទុកផង
មុខជាប្ដឹងហើយហោង    ថាឲ្យលែងមិនលែងឡើយ ។

## បទកំណោល

ប្រែបទពំនោលលោកអើយ សេដ្ឋីស្ដាប់ហើយ ក្រៅក្រោធពីកោធកោកក្រៃ ។
៤៨០-ញ័រមាត់រន្ធត់ដើងដៃ ស្រែកដេរថាថៃ ខ្មោចអាមេស្រុកប្រែស្រាល ។
អាឯងប្រយ័ត្នបែកក្បាល អាចោរអន្ធពាល មុខរឹងរបឹងមហិមា ។
អញហាមច្រើនដងច្រើនគ្រា ថាកុំឲ្យវា នាំពាក្យអានោះ ។
ឥឡូវអាទៅប្រាប់ចុះ ថាអញចង់លោះ នៃក្បាលវាមកកាប់ចោល ។
អញមិនខ្លាចអាក់អោល ក្បាលមួយតែលលោល ហ៊ានមកមើលងាយជាល្បែង ។
៤៨៥-មិនស្ញើរទេមុខអាឯង គ្មានព្រឺគ្មានស្លែង ឲ្យវាប្ដឹងចុះឥឡូវ ។
គាស់យកចាំងខ្មោចម៉ែឪ មកជួយក្ដីក្ដី កអញមិនមានព្រឺក្ដិត ។

អញឲ្យគន្ធសម្រិត មួយសៀនសុភចិត្ត ឲ្យស៊ីឲ្យមានកំលាំង ។
អាកូនមាន់មិនខ្លាចស្ទាំង ហ៊ានអួតតតាំង ជាញដល់មិនគិតជន្មា ។
នែអាមេស្រុកម្ហ៊ឹមា ចុះទៅប្រាប់វា ធ្វើពាក្យទៅថ្លឹងឲ្យធាប់ ។
៤៩០-មេស្រុកសោភលាប្រញាប់ ចុះដើរក្រឡាប់ ដល់ផ្ទះហ័សឡើងទៅ ។
ប្រាប់ពង្សពោធិសត្វនូវ ពាក្យពេចនាក់ជ្រៅ ប្រាប់មិត្រអស់ពពសង្ស័យ ។
ទើបពង្សពោធិសត្វថ្លៃ យកក្តារធ្នូនវៃ ដីសសរសេរពាក្យពេចន៍ ។
កាបរដាយគន្ធស្រេចគ្រប់ ស្រួលបួលស្រេចបាច់ បញ្ចុះក្រដាសធាប់ព្រៃ ។
ពិនិត្យត្រូវទិតថ្នាំងផៃ នាំមេស្រុកវៃ ចរចូលក្នុងកំង់ម្ហ៊ឹមា ។
៤៩៥-អស់ពលសកលយោធា មន្ត្រីសេនា កុំស្គាល់ជាម្ចាស់ឡើយនៃ ។
គិតស្មានក្សត្រក្សត្រានផៀសួជ័យ ស្តេចនិត្យនៅក្នុងមន្ទីរមណ្ឌលសោភា ។
កុំដឹងជាព្រះរាជា យកកៀសលីលា ទៅដល់តិចតួចឡើយនៃ ។
លុះយល់ព្រះបាទក្សត្រថ្លៃ កាន់ពាក្យចូលនៃ គិតថ្លៃតែក្នុងចិត្តជាក់ ។
និយាយនឹងគ្នាលួចលាក់ ថាហ្ន៎មើលអ្នក ដែលដើរកាន់ពាក្យទៅខ្លី ។
៥០០-កបកាយទ្រង់ព្រាយពិសី ដូចព្រះចក្រី ជាម្ចាស់លើត្បូងសិរសា ។
ខ្លះមើលយល់ហើយឆ្លើយថា មែនខែខពិតណា ប្រាកដសក្តិសមពុំឃ្លាត ។
ឯអន្តពង្សពោធិជាតិ ស្តេចចរខ្ញីឃាត ដល់ព្រះរាជរោងសោភា ។
កាន់ពាក្យនោះចូលម្ហ៊ីមា ជូនទៅពញា លុះលាមើលសព្វសេចក្តី ។
ព្រះពង្សទេវវង្សចក្រី អ្នកជយនៃឡើ អន្ទុយទីមួយសមគួរ ។



៥០៥-ទៅហ្វាធ្វើជាសាកសួរ គេស៊ុបដូរប្តូរ ថាអ្នកនារការជាអ្វី ។
ជាកូនព្រះស្តុបមន្ត្រី ប្តីកូនសេដ្ឋី ចូរស្រដីប្រាប់ឲ្យច្បាស់ ។
ក្សត្រាឆ្លើយថាលោកម្ចាស់ ខ្ញុំនាំក្រងណាស់ ហ្វឹងម្ចាស់ពុំឲ្យធ្វើឡើយ ។
ជាយុទ្ធមុនទេលោកអើយ តែហ្វឹងផ្គងហើយ ឲ្យស្តីជាខហ្វឹងកាយ ។
បានជាខ្ញុំគិតខ្វល់ខ្វាយ ស្តីក្នុងអ្នកអាយ គ្រាន់ជាំបាយទឹកអាស្រ័យ ។
៥១០-ក្សត្រប្រាណមានវេលាក្រៃ វេទនាពណ្ណសព្វថ្ងៃ អាស្រ័យនៅផ្ទះបានបាយ ។
ខ្សោយឲ្យទៅនិយាយ ស្តីក្នុងអ្នកអាយ តាមម្តាយឪពុកផ្តាំ ។
ខ្សោយបែរកើតទោសធំ ដូចមានក្នុងដំ- ណើរនៃពាក្យខ្ញុំប្រទាន ។
ម៉ែឪមានឈ្មោះជាអាច ក្នុងពាក្យជាក់ជាតិ កុំបាច់ខ្ញុំជំពបឡើយ ។
សម្តេចទៅហ្វាស្តាប់ហើយ ថាទៅថារ៉ុយ កម្រែកនាយវែងឯងទៅ ។
៥១៥-កោះយកខ្លួនសេដ្ឋីក្បៅ មកបាច់ខ្សោយ នេះឯងកុំឲ្យយូរយារ ។
បានការប្រកែកម្តេចម្តា កុំស្តាប់ឡើយណា នាំគ្នាព្រួតចាប់ឲ្យបាន ។
ចងស្លាបសេកបណ្តើរថ្កាន ហើយឯងកុំមាន អាសូរគេណាតិចកំ ។
ហើយពួកតម្រួតអាជ្ញា ហៅអស់គ្នីគ្នា ប្រមាណមួនដប់នាក់ ។
កាន់គ្រឿងកាំភ្លើងដាវផ្គាក់ ដើរទៅសស្រាក់ លន់លុះដល់ផ្ទះសេដ្ឋី ។
៥២០-ខ្លះឡើងខ្លះចាំនៅដី ខ្លាចក្រែងសេដ្ឋី ភិតភ័យលួចចុះរត់បាត់ ។
ហាមគ្នាឲ្យប្រុងប្រយ័ត្ន ក្សែតទោសធំក្តាត់ តែបាត់ត្រូវឯងពល់គ្នា ។
ឯអន្តនៃវែនអាជ្ញា ឡើងលើផ្ទះមហា- សេដ្ឋីអន្ទុយម្ហ៊ីមា ។

និយាយប្រាយប្រាប់ទៅថា ម្នាលសេដ្ឋីតា- ចាស់ចូរស្ដែងស្ដាប់ឲ្យជាក់ ។
ក្បែរលោកទៅហាយខ្ញុះ ប្រើយើងផៀងជាក់ គោះយកសេដ្ឋីឯងទៅ ។
ឲ្យឆាប់កុំបង្អង់នៅ សេដ្ឋីកម្សៅ ស្ដាប់ហើយឆ្លើយដណ្ដឹងថា ។
លោកប្អូនលោកកូនមេត្តា ប្រាប់ខ្ញុំពិចក គោះមានប្រការកលអ្វី ។
សូមកូនលោកគិតប្រណី ប្រាយប្រាប់សេចក្ដី បន្តិចឲ្យដឹងដើមក៏ ។
គ្រានោះតម្រួតអាជ្ញា ប្រាប់សេដ្ឋីថា ហៃតាចាស់ចូរស្ដែងស្ដាប់ ។
ក្បែរមានគេប្ដឹងសាសព្ទ ធ្វើពាក្យប្រជាប់ គ្រាអស់ក្រុមមុខមន្ត្រី ។
ជាចៅក្រសួងបញ្ជី ហើយជូនទៅខ្មី ចៅក្រមពិភក្ដរក្សា ។
ក្នុងពាក្យនោះយើងឮថា គេទំនឹងមហា- សេដ្ឋីធ្វើពុំគួរគាប់ ។
ឲ្យកូនគេហើយក្រឡប់ កែប្រែជាស្អប់ ផ្ដាច់កាច់កិនផ្ដេសផ្ដាស ។
មិនតែប៉ុណ្ណោះប្រឡះ ជេរគេជៀលត្មះ បន្ទោកបន្ទាបឥតកោត ។
កាលនោះឯសេដ្ឋីសោក ស្ដាប់ហើយរឹងក្រោធ ភិតភ័យរន្ធត់អស់ប្រាណ ។
ថាទុក្ខនោះប៉ុន្មាន ក្នុងតែទឹងបាន ដៃអញឥឡូវនេះឯង ។
សេដ្ឋីស្រដីឥតក្រែង ថាខ្ញុំមិនស្វែង មិនស៊ើបទេលោកប៉ុណ្ណោះ ។
ខ្ញុំត្រូវភាទៅបន្ទុស ដំណើរនោះ ខ្ញុំមានទៅស្គាល់កាលណា ។
មិនដឹងបន្តិចឡើយណា អស់លោកអាជ្ញា ស្ដាប់ចុះខុសឬជាត្រូវ ។
អាជ្ញាឆ្លើយថាច្បាះកូវ មានខុសមានត្រូវ បើលោកថាខ្លួនមិនដឹង ។
សេដ្ឋីថាការក្រតឹងហ្នឹង ខ្ញុំបាទសូមពឹង លោកកូនជួយទំនុកផង ។



រលងតែឈ្មោះវាជាម្ដង កុំភ័យឡើយហោង ខ្ញុំជូនប្រាក់ប្រាំណែនជាក់ ។
ឲ្យតែលោកជួយធុរៈ ជួយដោះចំពាក់ ឲ្យរួចស្រឡះពី ។
អាជ្ញាឆ្លើយថាកុំភ័យ បើប្លោះតិចតែ ឯងគោះដើរគោះនោះមក ។
សេដ្ឋីស្ដែងស្ដាប់ចាប់យក ប្រាក់តិចលែលក ត្រូវតាមទំនៀមដើងគោះ ។
ហើយឯគុណក្រៅទៀតស្មោះ គេឲ្យជួយដោះ កម្រងកម្រូវពាក្យពេចន៍ ។
ហើយប្រាប់រៀបខ្លួនស្រាប់ស្រេច អាជ្ញានាំក្រាប់ ចេញចុះលុះដើរដល់ទៅ ។
ឡើងលើចុងកេងនិត្យនៅ អស់មនុស្សខ្លះនៅ អង្គុយកាយរៀបរៀងគ្នា ។
ឯអគ្គសម្ដេចចៅហ្វា យល់យល់រោគមហា- សេដ្ឋីដល់ដូច្នោះហើយ ។
ប្រាប់ថាហៃសេដ្ឋីអើយ ឥឡូវចៅអើយ មានគេប្ដឹងអញជាក់ស្បាន ។
មានពាក្យគេចោទប្រកាន់ សម្លាប់ពុំមាន ឲ្យគោះសេដ្ឋីអង្គឯង ។
ឯគោតសេដ្ឋីស្ដាប់ស្ដែង មានវាចាវែង ក្រាបសម្ដេចចៅហ្វា ។
សូមទានប្រោសប្រាណមេត្តា សូត្រពាក្យនោះណា ឲ្យបានបើដឹងនឹងស្ដាប់ ។
ចៅហ្វាហៅស្មៀនប្រញាប់ ឲ្យសូត្រសាសព្ទ ពាក្យពេចន៍សេចក្ដីដាំអាក់-
ថាសូមទានមុនខ្ញុំបាទ កូមខេក្ដជាក់ជាក់ និត្យនៅនិគមគ្រាមា ។
មុនខ្ញុំសូមធ្វើពាក្យថា ដំណើរជោយនា ចំណាំនាំមកប្រណិប័តន៍ ។
ជូនលោកជាចៅហ្វាយថ្វាត់ សូមប្រោសក្បែរសព្ទ ថាខ្ញុំពុំសុខចិត្តខ្ញី ។
នឹងគោតមហាសេដ្ឋី ជាផ្សំកូនស្រី នាមឈ្មោះកេសរមាលា ។
ផ្គូផ្គងឲ្យខ្ញុំបាទថា ស្វាមីភរិយា កាលខ្ញុំពុំទាន់កើតកូន ។

សន្យានឹងគ្នាម៉ែឪ កាលគាត់រស់នៅ បានទៅបានមករកគ្នា ។
សន្មតប្រាកដប្រជា កូនធំកាលណា នឹងរៀបមង្គលការខ្ញី ។
សឹងមានកសិណសាក្សី បានដឹងសេចក្ដី ប្រាកដជាក់ជាវ្យក្ត ។
ឥឡូវនេះកូនម៉ឺនខ្ញុំ ពឹងគេចូលសុំ ដណ្ដឹងតាមច្បាប់បុរាណ ។
សេដ្ឋីគិតតែប្រប្រាណ ត្រឡប់ជាវេរក្ខាន គិតវៀចតាមតែចិត្ត ។
គិតនឹងកប់ពាក់អ្នកមហា ប្រទេចផ្កាសា ត្រឡប់គេជាមិនឲ្យ ។
ហើយថែមស្រែកជេរបណ្ដាយ បណ្ដេញតាមក្រោយ ហេតុនេះខ្ញុំបាទទំលក
កើតទុក្ខពុំសុខក្នុងចិត្ត នឹងសេដ្ឋីពិត សូមតានប់កើតទាន់ខ្មី ។
ប្រើកោះយកខ្លួនសេដ្ឋី មកហើយប្រណី ជំនុំជំរះឲ្យបាន ។
តាមច្បាប់ទម្លាប់បុរាណ ខុសត្រូវពុំគ្នា មែនមានខ្លួនខ្ញុំបាទស្រាប់ ។
ក្រែងពុំប្រាកដពុំគាប់ ពុំគួរនឹងច្បាប់ មុនខ្ញុំគូសថ្វាំងដៃឆ្វេង ។
សំពងជូនតាមច្បាប់ព្រេង កុំឲ្យលោកក្រែង ខ្ញុំបាទគេបកែសំដី ។
តាមពាក្យកំហឹងសំដី អស់ពាក្យនេះនៃ ពិតត្រង់ត្រឹមប៉ុណ្ណោះឯង ។
ស្មៀនសូត្រពាក្យប្ដឹងវែងស្ដែង សេដ្ឋីនោះឯង បានស្ដាប់សារសព្ទនោះណា ។
ក្រាបទៅចៅក្រមថា សូមតាមេត្តា ខ្ញុំបាទកាលគ្រានេះម្ដង ។
ពុំមិនធ្វើពាក្យឡើយហោង សូមសុំឆ្លើយស្នង ខ្ញុំព្រាងតែបានឬទេ ។
ឥឡូវនឹងគិតរិះរេ រិះរកស្ដីគេ សរសេរធ្វើជាពាក្យពេចន៍ ។
បល់ជាយូរយារបន្តិច ចាំគិតកលកិច្ច នឹងខ្ជិលរវល់សោះសោ ។



សម្ដេចចៅហ្វាឆ្លើយថា ឆ្លើយតាមចិន្ដា នរណាគេនឹងថាអ្វី ។
កាលនោះឯងឯសេដ្ឋី បានស្ដាប់សំដី សម្ដេចចៅហ្វាផ្ដាំ ។
ថ្លាថ្លោះចំពោះហើយណា អរក្នុងចិន្ដា ហើយឆ្លើយខ្ញុំប្របាទ ។
ពីក្នុងដល់តាស់ជាអាទិ៍ ពុំដែលស្គាល់ជាតិ គ្នានោះផលំពិចឡើយណា ។
ឥឡូវនេះក្ដីវាថា ខ្ញុំបាទនេះណា បានលើកកូនឲ្យវាខ្មី ។
ថាមានទាំងស្មរ[១]សាក្សី ចាំជាក់សេចក្ដី បានដឹងប្រាកដប្រជា ។
នរណាមួយបន្ទាល់វា ចេញឈ្មោះម្នា នឹងអាលបានដឹងជាក់ជ្រៅ ។
សម្ដេចចៅហ្វាសួរទៅ ពន្យពាលវៅ ថាហៃអ្នកម៉ឺនចៅក្ដី ។
ឥឡូវនេះក្ដីសេដ្ឋី ទាក់ក សាក្សី ដែលអ្នកម៉ឺនចោទចំពោះ ។
ចូរចែងសំដែងប្រាប់ឈ្មោះ នឹងកាលពិគ្រោះ ជំនុំឲ្យដឹងចាញ់ឈ្នះ ។
ក្យក្រៅថ្វាលើកដៃសំពះ ឆ្លើយថាលោកម្ចាស់ រឿងបន្ទាល់នោះខ្ញុំ ។
ជាកូនមេបាសេដ្ឋី នេះឯងនាងស្រី បានដឹងបានឮផងណា ។
តើច្បាប់ទម្លាប់មាត្រា អំពីការជា បុរាណយកបានឬទេ ។
ខ្ញុំបាទកើតក្ដីនឹងគេ ហើយមកយកឯ កូនគេជាតិជាសាក្សី ។
សម្ដេចចៅហ្វាស្ដាប់ស្ដី ឆ្លើយថាមានអ្វី យកកូនអ្នកក្ដីមកម្ដង ។
ធ្វើជាសាក្សីសំអាង ពាក្យពេចន៍ល្អយ៉ាង មិនមានទាល់តាក់ថ្នាក់អ្វី ។
ទើបប្រាប់ទៅមហាសេដ្ឋី ថាវីសាក្សី នោះត្រូវកូនស្រីខ្លួនឯង ។

---

១ – អ្នកដែលនាំពត៌មានពីសាក្សីមកប្រាប់ដល់អ្នកមានខ្លួន, សាក្សីបន្ត , ស្មរ បន្ទាល់ ។

ជាតិជាស្នេហ៍ពេញស្នេហ៍ខេន សេដ្ឋីស្ដាប់ស្ងួន ក្រេកអរក្នុងចិត្តគិតថា ៗ
៥៩៥–កូនកញ្ញាបងពិតណា គឺមេះតែថា កាលណាក់ខឹងជាដឹង ៗ
សមកូនអញឆ្លើយផ្សឹង ៗ រឹតអញខឹង ខឹងឈ្នះប្រាកដជាម្ដង ៗ
គិតហើយសេដ្ឋីសាសង សាសព្វនឹងស្ងួន ដំពបសម្ដេចចៅហ្វា ៗ
ចាំបើយកកូនខ្ញុំជា សាក្សីចុះណា ឲ្យលោកសង្កាត្រង់ហ្នឹង ៗ
ចុះបើចន្ទាល់ឆ្លើយផ្សឹង ពីពាក្យអ្នកហ្នឹង អស់លោកឲ្យខុសត្រឹមណា ៗ
៦០០–ចៅក្រមឮសេដ្ឋីថា ល្អោះហើយសួរសា ចៅពន្សំពារប្រសើរ ៗ
ហៃអ្នកខ្ញុំមិនជាបើ សាក្សីទុលទេរ ឆ្លើយខុសពុំត្រូវពាក្យអ្នក ៗ
ជានឹងទទួលធុរៈ ឲ្យចៅក្រមជាក់ ធ្វើទោសត្រឹមណាចូរវេន ៗ
ព្រះពោធិវង្សស្ដាប់ស្ងួន ឆ្លើយថាខ្ញុំឯង បើចាញ់ក្ដីមហាសេដ្ឋី ៗ
សូមឲ្យកាប់កាត់សិរសី ហើយដាក់ឡើងឆ្នី នៅមុខព្រះលានក្បាត្រា ៗ
៦០៥–យកឈ្មោះសរសេរអក្ខរា ព្យោះតាំងសតថា ប្រាមប្រាប់ប្រជាជនផង ៗ
កុំឲ្យធ្វើតាមឡើយហោង ដូចខ្ញុំនេះម្ដង ឲ្យដឹងឲ្យចាំពលគ្នា ៗ
កូនគេចៅគេជា ៗ ឯងហ៊ានបំពារ បំពាក់បំពានថៃថា ៗ
គេលើកផ្សំឲ្យគ្នា មិនតែម៉េះណា វាមកប្ដឹងដល់ចៅក្រម ៗ
ឲ្យគោរគេមកជុំ ក្រទាសដោយជំ ណើរនោះលុះចាញ់ក្ដីគេ ៗ
៦១០–ហេតុនោះកុំអ្នកគាន់គេ ផ្សុសល្ងៀវចាវ ដូចមុនខ្ញុំបាទនេះឡើយ ៗ
សម្ដេចចៅហ្វាស្ដាប់ហើយ ទៀនទើបក្មាស់ឆ្លើយ ស្មារតីសេដ្ឋីនោះថា ៗ



សេដ្ឋីឯងតែម្ដងម្ដា ហើយពិភាក្សា សួរសាក្សីសោតឆ្លើយសោ
ឆ្លើយទៅហៅត្រូវចំពោះ ដូចពាក្យមុននោះ គេទទួលខុសយ៉ាងណា ៗ
សេដ្ឋីដំណេចទៅថា បើពិភាក្សា សេចក្ដីឲ្យចៅខ្ញុំបាទ ៗ
១៥- កាប់បុណ្យចាញ់តែជាជាតិ ឲ្យធ្វើដល់ខ្មាត កាត់កជិតក្បាលតាមទោស។
កុំឲ្យលោកមានសន្ដោស ប្រណាប្រណីប្រោស ខ្ញុំដល់គិតគួរឡើយណា
ចៅក្រមកត់ពាក្យសត្យា ពាក្យពេចន៍សន្យា ចាញ់ឈ្នះស្រឡះហើយហោង ៗ
ចៅហ្វាប្រើកូនក្មួយផង ឲ្យរត់ទៅផ្លង ប្រាប់ស្រីសុគន្ធនាយកូស ៗ
ឲ្យយកតែយានទៅស្មោះ អញ្ជើញស្រីស្រស់ ជាកូននៃគោតសេដ្ឋី ៗ
៦២០–ឲ្យមានក្រុមកាំងទៅខ្មី ហៃហមអមស្រី កុំឲ្យប្រហែសឡើយណា ៗ
កូនក្មួយរួសរាន់រួសរ៉ាក់ ប្រាប់ស្រីទុកញ៉ា សុគន្ធដូចដោយបន្ទាប់ ៗ
អស់នោះរួសរៀបប្រដាប់ គ្រឿងគ្រប់ស្រេចស្រាប់ ហើយទើបតាំងយាត្រា។
ដល់ផ្ទះសេដ្ឋីបិតា ខ្វះឡើងមីម្នា ដំពបនាងថាលោកម្ដាយ ៗ
ថាអ្នកសូមប្រាបក្នុងកាយ កុំគិតទ្រល់ធ្លាយ ផង្សូវនេះសម្ដេចចៅហ្វា ៗ
៦២៥-លោកប្រើអស់យើងរាល់គ្នា មកចាំងនេះណា ឲ្យអញ្ជើញនាងស្រីថ្លៃ ៗ
ជាបុត្រនៃអ្នកឯងនៃ ឲ្យទៅនាំរ៉ៃ ត្បិតពាក្យអ្នកក្ដីខាងគាង ៗ
ទានមកប្រកាន់ដល់នាង យកជាសំអាង សាក្សីទិព្វពេជ្ញាណ ៗ
សម្រេចឈ្នះចាញ់នៅប្រាណ នាងនាថកល្យាណ ចូររៀបខ្លួនប្រាណខ្មីខ្មា ៗ
កុំឲ្យបន្ទង់យូរយារ វង្សនាងជា ប្រពន្ធសេដ្ឋីឮហើយ ៗ

៦៣០– ប្រើខ្ញុំស្រីពុំលន់ឡើយ ថាហៃបងអើយ ទៅប្រាប់គេសរមាលា
ឲ្យរៀបខ្លួនប្រាណម៉ែម្នា កុំឲ្យយូរយារ ក្សិតមានចុះលើខ្លួន ។
នាងប្រាប់សាសព្វថែថ្នម តាមដឹងមែនមួន ឥតខ្វះកន្ទះឡើយណា ។
ពាសីឃ្លាតខ្ញីយាត្រា ចូលក្នុងប្រាង្គប្រា- សាទនាងទៅស្រីថៃ ។
ដល់ហើយអង្គុយលើគ្រែ សំពះនាថថៃ ជំពប់សព្វគ្រប់ប្រការ ។
៦៣៥– នាងស្តាប់សាសព្វហោះណា ដឹងក្នុងចិន្តា នឹកថាទុប្រែសពន្លក ។
សមបានជាជុំទើបមក ប្តីផ្តល់គោះយក សេដ្ឋីចិត្តាខ្ញុំ ។
ប្អូនស្រីហៅមហាចប់ធំ ក្នុងទ្រូងប្អូនក្រុំ ដូចគំរលំលើខ្លួន ។
ជួនពេកបម្រែកមែនមួន ទុក្ខមោព្រួយព្រួន កម្រែកែបរបខណា ។
ឲ្យស្រាលស្រយាលទុក្ខា របូតកាយា រេបរពីក្តីសៅហ្មង ។
៦៤០– ឲ្យកើតមកជាមនុស្សម្តង ក្នុងជាតិនេះហ្មង យ៉ាងសែនលំបាកចិត្តប្រែ ។
ហេតុតែនាងនាថស្រីថៃ ជាតិជាកន្សែ សិរីសពេជ្ញតាញាណ ។
គិតយល់រំពេចពុំមាន ទល់ទុក្ខក្នុងប្រាណ កល្យាណនាងតែងគ្នា ។
ប្រាប់ស្រីប្រាំបីនាក់ណា ដែលទុកចិន្តា ដឹងការណ៍ដឹងកលនេះនៃ ។
ឲ្យតែងខ្លួនប្រាណទំនៃ នាងបរបញ្ជៃ ដើរដល់មណ្ឌលមាតា ។
៦៤៥– ក្បៀណនោះឯអង្គមាតា អញ្ជើញកល្យាណ៍ លីលាជិះគ្រែបញ្ចេញទៅ
គស់ខ្ញុំហោមផ្ទុំខ្លួនទៅ កាន់អស់គ្រឿងគ្រៅ ប្រគប់គន្ធារទីកោ ។
គស់ក្រស្តាន់ផ្កាសមើលគោ សរសើរជាទ កូនមហាសេដ្ឋីនេះណា ។



គបកាយទ្រង់ព្រាយរូបា ល្អផូបទេវតា ប្បុគស្រុតមកជាម្តង ។
គ្រកាលលើសអស់មនុស្សផង មើលទៅគ្មានផ្គង ពាក់ទាំងទើសក្អែកគ្រឹងណា ។
៦៥០– មនុស្សផងអឺងកងយាត្រា តាមមើលធីតា ភ្លេចកូនភ្លេចទៅទាំង ។
លង់លុះចរចូលរាំងវៃ ដល់ពរក់ជ័យ ទើបដាក់នាងនាថកល្យាណ ។
ឡើងទៅអង្គុយនាស្ថាន មួយសមគួរបាន សំពះសម្តេចទៅហោង ។
បាំងនេត្រសង្កេតតាជា រកមើលកស្តា ឃើញជាក់ជាក់មុខវៃឆ្នា ។
ក្នុងចិត្តនឹកគិតបង់ស្តី រិតខ្លាចសេដ្ឋី ស្រស់ស្រីពុំហ៊ានតាំងការ ។
៦៥៥– ឯអង្គពូជពង្សពុទ្ធា យល់នាងសោភា រាជាព្រឺព្រួចក្នុងប្រាណា ។
ដោយនឹករលឹកកល្យាណ ស្មើទេចពុំបាន ចង់តែទៅថ្នាក់ថ្នមស្រី ។
ពាស់ភ្នាសអស់មុខមន្ត្រី មួយទៀតក្សិតក្តី ពុំពាន់ស្រឡះឈ្មោះពាញ់ ។
ព្រះទ័យមមៃភ្នាន់ភ្ញាញ់ កន្ទេងកញ្ចាញ់ សង្កាញ់សង្កេតចិន្តា ។
ទំទប់ព្រះទ័យក្សត្រា ធ្វើពុំនាំពារ ហាក់ជាមិនដឹងមិនយល់ ។
៦៦០– ទៅហ្មាឃើញព្រះទសពល និងដោយយោបល់ តពន្ធល់តពន្ធាយឡើយណា ។
ទៀងទើបសួរទៅនាងថា ហៃនាងធីតា ចូរនាងឆ្លើយតាមសុចរិត ។
កុំតែលបលាក់បាំងបិទ គេចង់សួរចិត្ត តើនាងបានដឹងឬទេ ។
ក្សត្រអង្គកម្មុននេះគេ ប្តីឲ្យគោះសេ- ដ្ឋីជាផុតនាងហោង ។
ជាក្សត្រកាលមុនជាម្តង លើកនាងនួនល្អង ផ្សំផងនឹងគេជាប្តី ។
៦៦៥– ថានាងដឹងជាក់សេចក្តី មែនឬចូរស្តី ឲ្យជាក់កុំលាក់ឡើយណា ។

បើពុំបានជឿនសោះសា សុំឲ្យធីតា នាងថាតាមដោយពិតត្រង់ ។
ក្បិតអ្នកទៀងតាំងតែអង្គ សង្កាពាក្យត្រង់ ហើយថាបើបម្លើយសាក្សី ។
ត្រូវដូចពាក្យពេចន៍សេដ្ឋី យើងកាត់សេចក្តី ឲ្យអ្នកមុខបាញ់បំពោះ ។
ហើយត្រូវកាត់ក្បាលមុខនោះ ដាក់ដោតចំពោះ បញ្ឈរនៅមុខព្រះលាន ។
ធ្វើតាមទោសខុសមែនមាន មួយបើកលក្ខណា ធ្វើយត្រូវនឹងអ្នកមុននោះ
ត្រូវឯឪពុកនាងខុស ធ្វើការមកហុស ត្រូវកាប់ដោតក្បាលដូចគ្នា ។
នាងស្តាប់សម្តេចចៅហ្វា សួរដូច្នោះណា ធីតាស្មៀមពុំស្រដី ។
លុះសួរគំលប់ពីបី ទើបស្រស់ស្រី នាងចេះតែស្មៀមសោះសា ។
ចៅហ្វាយល់ដូច្នោះណា ធ្វើខឹងសម្បា ថាឱអ្នកនាងពិសី ។
សួរទៅពេលយមាត់មិនស្តី គរខុស្តី កំបាំងជាស្មៀមមិនឆ្លើយ ។
នាងថាចៅហ្វាដូច្នោះហើយ ពិតពុំគោរតើយ តតបវិលទៅវិញស្ងួន ។
ខ្ញុំគិតគ្នាទក្តាញ់កន្ទង ភ្នាសអស់អ្នកផង ក្បិតខ្លួនកើតមកជាស្រី ។
ខឹងគេម្តងក្នុងលោកិយ នេះពេញអប្រិយ ចង្រៃពុំត្រូវនឹងគេ ។
ឯក្តីឱប្អាប់កាប់គេ្តី កាប់កិនវែវ ឲ្យឪពុកម្តាយមានទុក្ខ ។
ជាស្រីស្រីបស្រាលសោកទុក រលាតចាំឪពុក កើតក្តីកើតក្តៅវិការ ។
មួយទៀតពុំទាន់បានការ តែលោកឲ្យមក បានជាខ្ញុំស្មៀមមិនឆ្លើយ ។
សម្តេចចៅហ្វាស្តាប់ហើយ សួរថានាងអើយ នាងចង់បានការយ៉ាងណា ។
ចូរនាងប្រាយប្រាប់ដាប់ពី ឲ្យជឿនកលការណ៍ តែការដែលនាងចង់បាន ។



ទើបនាងឆ្លាស់ឆ្លើយទៅថ្កាន ថាខ្ញុំសូមទាន តែការប្រការមួយនៃ ។
ឲ្យមាត់ខ្ញុំចិញ្ចប្រវែង មានគេជជៀសជ័យ ថាម្តេចបានដូចចិត្តា ។
បើលោកអញ្ជាតមេត្តា ឲ្យការនេះណា ទើបខ្ញុំជីកបកាមពិត ។
សម្តេចចៅហ្វាពិនិត្យ ពិចារណាគិត នឹងអស់មន្ត្រីតាំងឡាយ ។
ថាឥឡូវនាងនោមនាយ ពិតពុំប្រាប់ប្រាយ ព្រោះក្បិតពុំទាន់បានការ ។
បើយើងឲ្យដោយសាទរ តាមចិត្តនាងវរ នោះទើបនាងឆ្លើយដោយពិត ។
មន្ត្រីទៃទៃរះគិត ព្រមគ្រប់គំនិត ដំណបទៀងទៅចៅហ្វា ។
សូមទានអស់យើងពល់គ្នា គិតសមគួរថា នឹងឲ្យទៅនាងនាថចុះ ។
សម្តេចចៅហ្វាស្តាប់ហ្នោះ ឆ្លាស់ឆ្លើយថានុះ លោកអត់ទោសឲ្យខ្ញុំហើយ ។
ខ្ញុំក៏មិនមានថាឡើយ អរពេកជាត្រើយ ទឹងកាលបានស្រេចសេចក្តី ។
ទើបប្រាប់ទៅនាងពិសី ថាហែនាងស្រី ចូរនាងទទួលយកការ ។
យើងបើកឲ្យដោយសាទរ តែនឹងតាមដោយធម៌ សច្ចំទទួលអំណរ ។
ទើបស្រស់ស្រីបវរ ក្នុងចិត្តត្រេកអរ ក្បិតបានដូចចិត្តប្រាថ្នា ។
ទើបនាងវាសភាន់ចរចា ជំរាបអស់មហា- មន្ត្រីតូចធំទាំងពួង ។
គ្រប់ក្រុមគ្រប់មុខក្រសួង បណ្តាខ្ញុំហួង ឲ្យជួយចាំជាសាក្សី ។
នាងថាឱលោកមន្ត្រី ទោះធំតូចក្តី អម្បាលនៅក្នុងពេងរមៀ ។
មេត្តាជួយចាំអង្គខ្ញុំ ក្បិតលោកជាធំ លោកឲ្យនូវការខ្ញុំឯង ។
ថាឲ្យមាត់ខ្ញុំចិញ្ចេន ប្រាកដដាក់ស្តែង កុំយៀងពុំឃ្លាតឡើយណា ។

ពោះមនុស្សពោះសត្វបក្សា មានទោសទុក្ខា ជាអាក្រក់ដល់ក្សណក្ស័យ ។
គេផងមាត់ខ្ញុំចិញ្ចឹមថ្លៃ សូមឲ្យនឹកក្រៃ ថារស់បានរស់ដូចមាត់ ។
ចៅហ្វាថាបានប្រាកដ យើងឲ្យកំណត់ សាក្សីដូចចិត្តចិន្តា ។
១៤៥–ចូរនាងឆ្លើយឲ្យឆាប់ក្រ ទីនកាលកាត់គាថ សេចក្ដីនេះឯងឲ្យឆាប់ ។
គាកាលណាបានស្ដាប់ ទើបនាងឆ្លើយប្រាប់ ថាសូមទានអស់លោកជ្រាប
សេចក្ដីនៃខ្ញុំផឹកប តាមដោយសុភាព កុំឲ្យលោកសង្ស័យសោក ។
ពាក្យអ្នកមុនគេពោល ត្រង់គ្មានបញ្ឆោត ប្រាកដឥតឯល្អៀងក៏ ។
ប៉ុន្តែឯអន្តបិតា គាត់ប្រែវាចា ព្រោះជាសេដ្ឋីឪពុក ។
១៥០–ឲ្យទានផនធានមិនទុក ទៀតទាល់តែទុក្ខ ក្សិណក្ស័យប្រល័យជីវិត ។
ក្រាក់សត់ទុជន ឥតមានទ្រព្យធន ឥតមាននរណាកាបកាន ។
ពុកខ្ញុំមកប្រែប្រាណ ប្រែប្រាសចេញឋាន គៀតយល់ទុក្ខពេកក្ដាក់ ។
ថាទៀយតែចិត្តគាត់ ស្អប់អ្នកក់សត់ ស្រឡាញ់ណាស់តែអ្នកមាន ។
ពានមនុស្សនៅក្នុងភូមិឋាន សោកសិទ្ធកប់កាន ស្រឡាញ់អ្នកមានទ្រព្យ ។
១៥៥–ខ្ញុំខ្ញុំសមានយសសក្ដា កប់អានឈ្មួធា ទៅមករកពុំដែលដាច់ ។
សេដ្ឋីពុធនាងឆ្លើយស្រេច រីងញ៉ាសុរាសាច់ ស្រែកជេរទៅនាងពាប់ថ្ងៃ ។
កាន្ទាបមេកូនចង្រៃ បង្អាបគញាទៃ ឲ្យអញខ្មាសគេជាម្ដង ។
ហើយទីងទៅទឹងក្សត្រប្សង ពេករាន់កន្ទង ខប់ខល់ពុំបានឡើយណា ។
ស្រែកជេរតាមចិត្តចិន្តា ដោយក្រៅក្រោធា មោហាមិនមានគិតអ្វី ។

Khmer Story Lovers



១៦០–ផឹកបរពៅចៅហ្វាខ្ញុំ សូមទានប្រណី ប្រោសប្រាណខ្ញុំបាទម្ដងចុះ ។
ខ្ញុំបាទជូនប្រាក់លោកម្ចាស់ ថ្លៃហាបប្រាស់ សូមទិញគាដៃដ៏ផុះណា ។
យកទៅកាច់ចោលសោះសា តាចោររមាហា បោកបាំងដាក់ស្នេហ៍ខ្លួនអញ ។
ឲ្យបាក់ចិត្តឈប់ស្រឡាញ់ ទៅវាំងនោះមិញ ឲ្យឆ្លើយត្រូវទីងពាក្យវា ។
តែអញនេះមិនកំព្រា តែខ្ញុំនានា ទៅជាសូលដ៏មិនខាន ។
១៦៥–ឯណានោះតាធ្វើបាន កាមប្រាជ្ញប្រាណ មិនមានអាណាចិត្តអ្វី ។
ឯងមករឿងគោគសេដ្ឋី មិនដឹងទេរី មិនល្បីខ្ទប់ដៃជា ។
កាលនោះសម្ដេចចៅហ្វា ក្រោធក្រៃមហិមា នេត្រាក្រហមដូចភ្លើង ។
ស្រែកថាអស់គាត្រាយើង រត់ទៅចាប់ឡើង ហៅគម្រូតមកចាប់ខ្ញុំ ។
ចាប់យកខ្លួនតាសេដ្ឋី នេះទៅចាប់ខ្ញុំ ហើយនាំទៅកាច់មីមា ។
១៧០–តាចោរតាងមានទ្រព្យា ជេរគេចំពោះ បំពានមិនមានកោតក្រែង ។
អញមិនឃ្លានប្រាក់តាឯង តាធ្វើជាល្បែង ក៏ហែងតាងមានទ្រព្យា ។
រីកូនក្មួយអ៊ីមីមា ដល់ថៃហើយណា ទៅបានគម្រូតចាប់ខ្ញុំ ។
ទៅដល់ចោមចាប់សេដ្ឋី ចងដាក់ជាក់ក្ដី ហើយទើបយកលលាដ៍ជូន ។
ទោកមាត់សេដ្ឋីពុធជូន ស្រែកយំលួន ឈាមទឹកភ្នែកស្រក់ស្រោច ។
១៧៥–ស្រែកហៅកូនពៅដើមទ សាម្មនដូចខ្មោច ថាឱមាសឪពុកអើយ ។
ឪពុកមុខជាស្លាប់ហើយ ឱមាសឪពុកអើយ ទៅផ្ទះប្រាប់ម៉ែឯងផង ។
ឲ្យបានដឹងដានចំនង ថាឪពុកឯង ខ្លួនទោសធ្ងន់ពេកក្រាស់ក្រៃ ។

លោកបិនបំណាំឲ្យក្បួយ ជីវិតប្រល័យ ក្នុងថ្ងៃនេះឯងព្រាកដ ។
ទរទកូនកែវកំសត់ កូនអើយបើអត់ ពិតពីឪពុកទៅហើយ ។
៧៤០– កូនកុំប្រហែសខ្លួនឡើយ មាសឪពុកអើយ ចូរអ្នកក្រក្តាយផង ។
កុំឲ្យមានកើតសៅហ្មង គឺជមនុស្សម្នាផង ខ្លួនល្អនាន់ទំរក្សា ។
ធ្វើម្ដេចជាកម្មបិតា មកឲ្យជួសការណ៍ ដល់ក្សួយប្រល័យជីវិ ។
នាងយល់អស់មុខមន្ត្រី ធ្វើទោសសេដ្ឋី ជាតិជាឪពុកនាងណា ។
នាងភ័យភិតក្រៃសោះសា សែនសោយសោកា ណាល់ទឹកអាណិតឪពុក។
៧៤៥ ក្នុងចិត្តក្តៅក្តួលជាទុក្ខ ញ័រពោះផ្អក ។ ក្តៅក្តួលរំជួលចិន្តា ។
ទនកាយលើកដៃវន្ទា សម្ដេចចៅហ្វា ជំរាបថាសូមលោកម្ចាស់ ។
ឪពុកខ្ញុំមានទោសក្រាស់ ទុក្ខធ្ងន់ក្រឡាស ត្រូលៀសលៀសពាកឡើយណា ។
ធ្ងន់ក្រៃត្រូវក្បួយជីវ៉ា ឥឡូវខ្ញុំថា ឪពុកឲ្យមានជីវិត ។
ចៅហ្វាធ្វើយថាកុំគិត កុំភ័យតាំងភិត យើងមិនឲ្យក្បួយទេនាង ។
៧៥០– ធ្វើតាមតែពិតឲ្យរាង កុំឲ្យភ្លាំចអាង អ្នកមានសម្បត្តិឯងកាច ។
ល្បាទពាទមិនកោកមិនខ្លាច គិតកែងកោងកាច មិនគិតក្រែងគេប៉ុនល្អង ។
ចៅហ្វាប្រើកម្រួកផង យកខ្សែមកចង សេដ្ឋីទៅក្រោយទៅមុខ ។
ហើយដាក់ប្រវក់ត្រាទុក ប្រាប់ចៅហ្វាយគុក ឲ្យនាំបណ្ដើរអាក្រាស ។
ធ្វើម្ដងឲ្យធួនតាមទោស កុំឲ្យសេដ្ឋាស ប្រណីអាសូរករុណា ។
៧៥៥– នាយវេនកម្រួតគេថា ទៅប្រាប់កញ្ញា ពេជ្ជតាខ្ញូវស្រីនគរបាល។

Khmer Story Lovers



ជល់ហើយសំណោះសំណាល ប្រាប់កិច្ចការកាល ដើមហេតុពីមហាសេដ្ឋី ។
បកភ័យជាយតាញ់ក្តី លោកចៅហ្វាថ្មី ឲ្យធ្វើទោសផ្តាលប្រយ៉ៅ ។
លោកប្រើខ្ញុំអញ្ជើញទៅ យកអស់គ្រឿងគ្រៅ សម្រាកអាត្មានោះផង ។
យកមនុស្សគ្រប់គ្រាន់ជាម្ដង ប្រញាប់កុំផ្សង បង្អង់ឲ្យយឺតយូរយារ ។
៧៦០– ឮគេលោកសម្ដេចចៅហ្វា នៅលើពន្ធា រង់ចាំនៅនោះទេណា ។
កាលនោះទុកញ៉ាំពេជ្ជតា ចាំងពីរភ្ញាក់ផ្អើរ ហាក់ស្លាប់ស្មារតីស្លៃ ។
ស្រូវរៀបគ្រឿងផងវៃ ។ ហៅគ្នាទាំងខ្ញុំ គ្រប់គ្រាន់ចំនួនមួយរយ ។
នាំគ្នាលីលាដើយ ដើរលឿនលយ លន់លុះដល់ចុងកេងទៀ ។
អង្គុយមិនលោកដាំង ចាំស្ដាប់ផង កាលនោះចៅហ្វាជាត្រើយ ។
៧៦៥– សួរថាពេជ្ជតាមកហើយ ទើបពេជ្ជតាឆ្លើយ មកហើយព្រះបាទជាម្ចាស់ ។
កាលនោះចៅហ្វាព្វចក្រស់ បង្គាប់ហ៊ាស ថាខែនគរពេជ្ជតា ។
ឯងនាំសេដ្ឋីមោហា បណ្ដើរដោយផ្ការ ឲ្យស្រែកការក្រោសជាម្ដង ។
ប៉ាវគងប្រាមប្រាប់អ្នកផង ឲ្យដឹងដោយផង ចំនងជំណើរនោះណា ។
ត្រានោះនគរពេជ្ជតា ស្ដាប់ហើយយាត្រា ដល់មហាសេដ្ឋីហើយយាង ។
៧៧០– ចងគ្រឿងប្រាំប្រការផង រាយគងហើយហោ ឲ្យសេដ្ឋីស្រែកអាក្រាស។
បណ្ដើរប្រាប់ជនស្រីប្រុស ក្នុងបុរីនោះ ឲ្យគេបានដឹងកាលគ្នា ។
សេដ្ឋីស្រែកខ្ញុំថៃថា ឲ្យអស់ទាំងមហា- ជនានុជនប្រុសស្រី ។
ចូរស្ដាប់កុំត្រាប់ខ្ញុំខ្មី ខ្ញុំមានកូនស្រី ស្ម័គ្រចិត្តគិតចង់ឲ្យគេ ។